មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០២០

| | |
|---|---|
| ឈ្មោះស្ថាប័ន | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") |
| គោលដៅ | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក គឺជាអង្គការឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការងារផ្តែកទៅលើគុណតម្លៃ សមភាព អព្យាក្រឹត្យភាព តម្លាភាព និងការមិនរើសអើង។ |
| រយៈពេល | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២០ |

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") អនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចមានរៀបរាប់ខាងក្រោម ៖

## ១. វឌ្ឍនភាពនៃសកម្មភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយចំនួន ៨៧ ពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមាន សេចក្តីថ្លែងការណ៍ លិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មានបន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន របាយការណ៍រួមដោយផ្តោតលើបញ្ហាជាក់លាក់ ប័ណ្ណព័ត៌មាន និងខិតប័ណ្ណព័ត៌មានមួយចំនួនទៀត។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងតស៊ូមតិ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនផ្សេងៗ រួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌និងសិទ្ធិជនជាតិដើមភាគតិចជាដើម។

ម.ស.ម.ក បន្តឃ្លាំមើលតាមរយៈសារព័ត៌មានក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានានិងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតទៅលើសិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្សជាទូទៅ សិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ («អ្នកស្រឡាញ់ភេទដូចគ្នា») និងស្ថានភាពនៃសេរីភាពមូលដ្ឋាននៅទូទាំងប្រទេស។ ជាសរុបក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក

បានប្រមូលព័ត៌មានសរុបចំនួន ១១៣២ អត្ថបទដែលចេញផ្សាយពាក់ព័ន្ធនឹងសិទ្ធិសេរីភាពមូលដ្ឋាន សេរីភាពខាងការជួបប្រជុំ សេរីភាពខាងការបញ្ចេញមតិ សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងសិទ្ធិស្ត្រីជាដើម។

ក្នុងរយៈពេលចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដល់ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ គឺជាយុទ្ធនាការ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមប្រធានបទ « គ្មាននរណាម្នាក់ត្រូវបានទុកចោល» ដែលបានប្រព្រឹត្តទៅចាប់តាំងពីទិវាអន្តរជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី រហូតដល់ទិវាសិទ្ធិមនុស្ស។ យុទ្ធនាការ ១៦ ថ្ងៃនេះមានគោលបំណងផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងដើម្បីបង្កើតលម្ហសម្រាប់ស្ត្រីមកពីវិស័យផ្សេងៗធ្វើការសម្តែង និងតស៊ូមតិដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។ ដើម្បីចូលរួមប្រារព្ធទិវាទាំងនេះ ម.ស.ម.ក បានបង្កើតយុទ្ធនាការរយៈពេល១៦ ថ្ងៃ រហូតដល់ទិវាសិទ្ធិមនុស្ស និងបានផ្សព្វផ្សាយសកម្មភាពនានាមួយចំនួនដូចខាងក្រោមនៅលើបណ្តាញសង្គម (ហ្វេសប៊ុក និងធ្វីតទើ) និងនៅលើគេហទំព័ររបស់ ម.ស.ម.ក ក្នុងបំណងលើកកម្ពស់ការយល់ដឹងអំពីស្ថានភាពសិទ្ធិមនុស្ស ជាពិសេស ទាក់ទងនឹងសិទ្ធិរបស់ស្ត្រី និងកិច្ចប្រឹងប្រែងរបស់សង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។

| ល.រ | កាលបរិច្ឆេទ | ការចេញផ្សាយឯកសារ |
|---|---|---|
| ០១ | ២៤ វិច្ឆិកា ២០២០ | សេចក្តីថ្លែងការណ៍ផ្សព្វផ្សាយអំពីយុទ្ធនាការជាភាសាខ្មែរ និងអង់គ្លេស។ |
| ០២ | ២៥ វិច្ឆិកា ២០២០ | ខិត្តប័ណ្ណព័ត៌មានៈ «ទិដ្ឋភាពទូទៅអំពីសិទ្ធិស្ត្រីនៅកម្ពុជា ឆ្នាំ២០២០» ជាភាសាខ្មែរ និងអង់គ្លេស។ |
| ០៣ | ២៥ វិច្ឆិកា ដល់ ៤ ធ្នូ ២០២០ | នៅលើទំព័រហ្វេសប៊ុកៈ ក្រុមការងារ ម.ស.ម.ក បានផ្សព្វផ្សាយដំណឹងអំពីការប្រកួតប្រជែង «រូបភាពពិពណ៌នាដំណើររឿង» នៅលើទំព័រហ្វេសប៊ុក ទាក់ទងនឹងអំពើហិង្សាទៅលើស្ត្រី ដោយអញ្ជើញទស្សនិកជនទាំងអស់ចូលរួមពិភាក្សាលើអត្ថន័យរូបភាពតាមសកម្មភាពពាក់ព័ន្ធក្នុងដំណើររឿង។ |
| ០៤ | ២៦-៣០ វិច្ឆិកា ២០២០ | វីដេអូខ្លីចំណងជើងថា «តើអ្នកយល់បែបណាចំពោះពាក្យថា អំពើហិង្សាទាក់ទងនឹងយេនឌ័រ?» ជាភាសាខ្មែរ និងមានអមសំណេរបកប្រែជាភាសាអង់គ្លេស។ |
| ០៥ | ២៧ វិច្ឆិកា ២០២០ | ការចេញផ្សាយខិត្តប័ណ្ណព័ត៌មានស្តីពី «កម្ពុជា និងដំណើរការពិនិត្យឡើងវិញនៃអនុសញ្ញា ស៊ី-ដ» នៅលើគេហទំព័រ-សិទ្ធិ របស់ ម.ស.ម.ក ជាភាសាខ្មែរ និងអង់គ្លេស។ |
| ០៦ | ២៨ វិច្ឆិកា ដល់ ៦ ធ្នូ ២០២០ | កម្រងរូបភាពរបស់អ្នកសារព័ត៌មានជាស្ត្រី មានរំលេចសារនៃការយល់ឃើញរបស់ពួកគេពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ |
| ០៧ | ០៤ ធ្នូ ដល់ ៩ ធ្នូ ២០២០ | នៅលើទំព័រហ្វេសប៊ុកៈ ក្រុមការងារ ម.ស.ម.ក បានផ្សព្វផ្សាយដំណឹងអំពីការចូលរួមការប្រកួតប្រជែងឆ្លើយសំណួរយករង្វាន់លើទំព័រហ្វេសប៊ុក។ |

| | | |
|---|---|---|
| ០៨ | ០៦ ធ្នូ ២០២០ | ខិត្តប័ណ្ណព័ត៌មាន: «អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅប្រទេសកម្ពុជា ស្ថានភាពបច្ចុប្បន្ន» ជាភាសាខ្មែរ និងអង់គ្លេស។ |
| ០៩ | ០៧ ធ្នូ ២០២០ | សលាកបត្រព័ត៌មាន: «សវនាការករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ស្ត្រីក្នុងតុលាការកម្ពុជា» ជាភាសាខ្មែរ និងអង់គ្លេស។ |
| ១០ | ០៨ ធ្នូ ២០២០ | កម្មវិធីពិភាក្សាវិទ្យុស្តីពី «ដំណោះស្រាយចំពោះអំពើហិង្សាក្នុងគ្រួសារ» មានផ្សាយបន្តផ្ទាល់នៅលើគេហទំព័រ ទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក និងតាមរយៈស្ថានីយវិទ្យុចំនួនប្រាំ។ |
| ១១ | ០៨ ធ្នូ ២០២០ | ខិត្តប័ណ្ណព័ត៌មាន: «អំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នាជាស្ត្រីនៅប្រទេសកម្ពុជា» ជាភាសាខ្មែរ និងអង់គ្លេស។ |
| ១២ | ១០ ធ្នូ ២០២០ | ការផ្សព្វផ្សាយកាលប្បវត្តិសិទ្ធិមនុស្សឆ្នាំ២០២០ នៅលើគេហទំព័រសិទ្ធិ ការបង្ហាញកាលប្បវត្តិនៃករណីរំលោភបំពានសិទ្ធិមនុស្សដែលបានកើតឡើងកាលពីឆ្នាំកន្លងទៅ ជាភាសាខ្មែរ និងអង់គ្លេស។ |
| ១៣ | ១០ ធ្នូ ២០២០ | ខិត្តប័ណ្ណព័ត៌មានចំនួន១២ ដែលបង្ហាញព្រឹត្តិការណ៍សំខាន់ៗក្នុងខែនីមួយៗក្នុងឆ្នាំ២០២០ ស្រង់ចេញពីកាលប្បវត្តិសិទ្ធិមនុស្ស។ |

ម្យ៉ាងទៀត គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានចេញផ្សាយព្រឹត្តិបត្រព័ត៌មានចំនួនបួន រួមមាន ៖ (១) សិទ្ធិសន្មតទុកជាមុនថាគ្មានទោស (២) សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ (៣) ការពន្យល់ប្រាប់សិទ្ធិ និង (៤) សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ព្រមទាំងបានចេញផ្សាយសលាកបត្រព័ត៌មានមួយផងដែរស្តីពី «សវនាការករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ស្ត្រីក្នុងតុលាការកម្ពុជា» និងចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំមួយស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ដែលមានបញ្ចូលនូវអនុសាសន៍មួយចំនួនទាក់ទងនឹងការពង្រឹងនីតិរដ្ឋ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់នៅកម្ពុជា។ ម.ស.ម.ក ព្រមទាំងបានចេញផ្សាយខិត្តប័ណ្ណព័ត៌មានមួយចំនួនផ្សេងទៀតផងដែរអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ សិទ្ធិស្ត្រី សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សេរីភាពមូលដ្ឋានធុរកិច្ច និងសិទ្ធិមនុស្ស។ ឧទាហរណ៍ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នៅទិវាអន្តរជាតិដើម្បីលើកកម្ពស់សិទ្ធិអ្នកប្តូរភេទ គម្រោងបានចេញផ្សាយសលាកបត្រព័ត៌មានមួយផ្សេងទៀតដើម្បីលើកកម្ពស់ការយល់ដឹងអំពីការរើសអើងដែលអ្នកស្រឡាញ់ភេទដូចគ្នាបានប្រឈមក្នុងការងាររបស់ពួកគេនៅប្រទេសកម្ពុជា។ សលាកបត្រព័ត៌មាននេះលើកឡើងនូវសម្រង់សម្តីរបស់បុគ្គលមួយចំនួននៅក្នុងសហគមន៍អ្នកប្តូរភេទ ដែលចែករំលែកនូវបទពិសោធន៍របស់ពួកគេនៅកន្លែងការងារ និងនៅពេលស្វែងការងារ។ ខិត្តប័ណ្ណព័ត៌មាននេះព្រមទាំងបានផ្តល់អនុ

សាសន៍មួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជា និងនិយោជកនៅក្នុងប្រទេសកម្ពុជាអំពីវិធីកាត់បន្ថយការរើសអើងលើអ្នកប្តូរភេទនៅកន្លែងធ្វើការផងដែរ។

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានរៀបចំការផ្សាយផ្ទាល់កម្មវិធីពិភាក្សាតាមវិទ្យុចំនួន ១៥៤ លើកដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញភាគីពាក់ព័ន្ធសំខាន់ៗពីសង្គមស៊ីវិល មេធាវីនិងរដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់របស់ពួកគេ។ រាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ផងដែរ ដែលមានអ្នកអាចទទួលបានព័ត៌មានចំនួន ១.៨៨៤.១៧៩ ទទួលបានការចុច Like ចំនួន ១៣.៣៧០ ចែករំលែកបន្តចំនួន ៦៧១២ និងចូលទស្សនាចំនួន ៣៣២.៨៩៣ ។

ម.ស.ម.ក បានរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលតាមដានបន្ត ទាក់ទងនឹងការតស៊ូមតិ ច្បាប់ ធុរកិច្ចនិងសិទ្ធិមនុស្សចំនួន១២ លើក ដោយមានអ្នកចូលរួមសរុបចំនួន២០៤ នាក់ (ស្ត្រីមានចំនួន១០២ នាក់ បុរសចំនួន ៧១ នាក់និងអ្នកស្រលាញ់ភេទដូចគ្នាចំនួន៣១ នាក់)។ លើសពីនេះក៏មានកិច្ចប្រជុំចំនួន១២ លើកផ្សេងទៀតផងដែរ រួមមានកិច្ចប្រជុំប្រចាំត្រីមាស ការប្រជុំចែករំលែកនិងការលើកកម្ពស់ការយល់ដឹងក្នុងចំណោមសហគមន៍ និងការចែករំលែកក្នុងចំណោមមេធាវី កម្មវិធីផ្សព្វផ្សាយ និងទិវាសិទ្ធិមនុស្សអន្តរជាតិដោយមានអ្នកចូលរួមចំនួន ២២៥(ស្ត្រីមានចំនួន១២៧ បុរសចំនួន១២៨នាក់។ ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងឆ្នាំ២០២០ ម.ស.ម.ក បានសង្កេតការណ៍សវនាការក្នុងករណីព្រហ្មទណ្ឌចំនួន១៨៥ ករណី នៅសាលាឧទ្ធរណ៍។

ម.ស.ម.ក ក៏បានផលិតវីដេអូអប់រំចំនួន ៤ រួមមាន៖

- វីដេអូបង្ហាញអំពីសារៈសំខាន់នៃតួនាទីរបស់អ្នកសារព័ត៌មានក្នុងអំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ (ចេញផ្សាយនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០)។
- នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ គម្រោងបានផលិតវីដេអូខ្លីនិយាយភាសាខ្មែរអមជាមួយសំណេរបកប្រែជាភាសាអង់គ្លេស ណែនាំអំពីតួនាទី និងអាណត្តិការងាររបស់អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម («អ្នករាយការណ៍ពិសេស»)។ វីដេអូនេះក៏ពន្យល់ផងដែរអំពីនិយមន័យនៃសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម ជាសិទ្ធិដែលអ្នករាយការណ៍ពិសេសប្តេជ្ញាក្នុងការលើកកម្ពស់។
- វីដេអូចំណងជើងថា សិទ្ធិខ្ញុំ យុត្តិធម៌ខ្ញុំ (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០)។
- វីដេអូខ្លីចំណងជើងថា ថាតើអ្វីជាអំពើហិង្សាទាក់ទងនឹងយេនឌ័រ? (ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០)។

លោកអ្នកអាចទស្សនាវីដេអូទាំងនេះនៅលើបណ្តាញសង្គមយូធូបនិងទំព័រហ្វេសប៊ុក របស់ម.ស.ម.ក។

## ២. ការប្រឈមនិងមេរៀន

ក្នុងកំឡុងពេលអនុវត្តគម្រោងក្នុងឆ្នាំ២០២០ ម.ស.ម.ក បានប្រឈមនឹងបញ្ហាមួយចំនួនទាំងក្នុងនិងក្រៅស្ថាប័ន។ ការប្រឈមនៅក្រៅស្ថាប័ន គឺបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានបង្កការលំបាកដល់ការអនុវត្តគម្រោងរបស់ ម.ស.ម.ក ជាពិសេសនៅក្នុងឆ្នាំ២០២០ ព្រោះបុគ្គលិកទាំងអស់របស់ ម.ស.ម.ក តម្រូវឱ្យធ្វើការងារពីចម្ងាយពីថ្ងៃទី៣០ ខែមីនា ដល់ថ្ងៃទី៣០ ខែមេសា ហើយលុះដល់ខែវិច្ឆិកា និងខែធ្នូមានការផ្ទុះឡើងនៃការឆ្លងទៅក្នុងសហគមន៍ក្នុងប្រទេសកម្ពុជា។ ដើម្បីសម្របទៅនឹងការរីករាលដាលនេះ ម.ស.ម.ក បានអនុវត្តនូវវប្បធម៌ធ្វើការងារបែបថ្មីមួយទាំងនៅលើអ៊ីនធឺណិត ឬការប្រាស្រ័យទាក់ទងគ្នាផ្ទាល់ អាស្រ័យទៅលើស្ថានភាពនៃមេរោគកូវីដ-១៩។ ម.ស.ម.ក បានអនុវត្តតាមសេចក្តីណែនាំរបស់រដ្ឋាភិបាលតាមរយៈការដាក់ឱ្យ អនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល ដូចជា សេចក្តីប្រកាសទាក់ទងនឹងការកំណត់ការប្រមូលផ្តុំ និងចំនួននៃអ្នកចូលរួមជួបប្រជុំជាដើមដើម្បីទប់ស្កាត់ការរីករាលដាលនៃការចម្លងក្នុងចំណោមអ្នកចូលរួម។

ដោយសារការរីករាលដាលនេះ សកម្មភាព ឬកម្មវិធីដែលបានគ្រោងរៀបចំមួយចំនួនបានធ្វើនៅលើអ៊ីនធឺណិតជំនួសវិញ ដើម្បីឱ្យស្របតាមវិធានការការពារសុវត្ថិភាពដែលមានសារៈសំខាន់នានា។ កម្មវិធីមួយចំនួនដែលគ្រោងរៀបចំឡើងក្នុងរយៈពេលចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២០ ត្រូវបានរៀបចំឡើងដោយមានការរឹតបន្តឹងសុវត្ថិភាព ស្របពេលដែលប្រទេសកម្ពុជាប្រឈមនឹងរលកថ្មីនៃការឆ្លងមេរោគកូវីដ-១៩ និងជាករណីឆ្លងចូលសហគមន៍ជាលើកទីមួយ។ ជាការឆ្លើយតប រដ្ឋាភិបាលបានហាមឃាត់ការប្រមូលផ្តុំមនុស្សមិនឱ្យលើសចំនួន២០នាក់ ហើយកម្មវិធីនានាត្រូវបានផ្អាករហូតដល់កាលបរិច្ឆេទសមស្របមួយទៅថ្ងៃអនាគតនៅពេលដែលហានិភ័យនៃមេរោគកូវីដ-១៩ បានស្រាកស្រាន្ត។

អង្គការមិនមែនរដ្ឋាភិបាលនៅតែត្រូវបានតម្រូវអោយបំពេញនូវលក្ខខណ្ឌរដ្ឋបាលមួយចំនួន ក្នុងនោះរួមទាំងការតម្រូវអោយរាយការណ៍ទៅអាជ្ញាធរ ឬអាជ្ញាធរចុះមកតាមដានកត់ត្រាព័ត៌មានពាក់ព័ន្ធនឹងព្រឹត្តិការណ៍សកម្មភាពដែលរៀបចំឡើងនៅតាមមូលដ្ឋាន ដូចជាកត់ត្រាប្រធានបទ របៀបវារៈ ចំនួនអ្នកចូលរួមនិងថតរូបអំពីព្រឹត្តិការណ៍ ឬអ្នកចូលរួមជាដើមដើម្បីរាយការណ៍ទៅថ្នាក់លើ ។

ថ្វីបើមានការប្រឈមការរឹតត្បិតយ៉ាងណាក្តី ម.ស.ម.ក យល់ឃើញថាការបន្តសកម្មភាពតស៊ូមតិប្រកបដោយគោលការណ៍ ដោយតុល្យភាព និងការចូលរួមក្នុងកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធជាកិច្ចការចាំបាច់ដើម្បីបន្តកិច្ចគាំពារនិងលើកកម្ពស់សិទ្ធិមនុស្ស។ ម.ស.ម.ក នៅតែប្រកាន់គោលជំហរប្រកបដោយគោលការណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ទស្សនៈមិនលម្អៀង និងតុល្យភាព។

## ៣. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ក្នុងឆ្នាំ២០២០ ម.ស.ម.ក នៅតែអនុវត្តសកម្មភាពការងាររបស់ខ្លួនដើម្បីធានាយ៉ាងណាដើម្បីឲ្យមានសមភាពយេនឌ័រ ជាពិសេសសការចូលរួមរបស់ស្ត្រី។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីស្ថានភាពផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០២០ យុទ្ធនាការ ១៦ ថ្ងៃដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការឃាយីនិងការគំរាមកំហែងដោយសារការងាររបស់ពួកគេ។

**៤. ឧបសម្ពន្ធ ៖** ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

- របាយការណ៍ស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩)។
- ខិត្តប័ណ្ណព័ត៌មានស្តីពី សេចក្តីណែនាំអំពីអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ជាភាសាខ្មែរ និងអង់គ្លេស។
- ខិត្តប័ណ្ណព័ត៌មានស្តីពី អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម ដោយមានលើកឡើងអំពីរបកគំហើញរបស់អ្នករាយការណ៍ពិសេស ព្រមទាំងមានពន្យល់អំពីនិយមន័យនៃសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងការចងក្រងសមាគមនៅយុគសម័យបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទំនាក់ទំនងរវាងសេរីភាពជួបប្រជុំ និងការចងក្រងសមាគម ហើយនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាភាសាខ្មែរ និងអង់គ្លេស។

--- ចប់ ---